# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ
ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2014, 15:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ
ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ
ឈ្មោះមន្ត្រីដែលបានពិនិត្យ
ហត្ថលេខា:

---

# ចម្លើយតបរបស់ នួន ជា ចំពោះសារណារបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រើ ព័ស្តុតាងពីសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
ព្រុំ ផល្លា
សួន វិសាល
លីវ សុវណ្ណា
Joshua ROSESWEIG

ផ្ញើជូន៖

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**
**លោកស្រី ជា លាង**
**លោក Nicholas KOUMJIAN**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
PICH Ang
Elisabeth SIMONNEAU-FORT

សហមេធាវីរបស់ជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារ") តទៅនេះឆ្លើយតបចំពោះសារណារបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រើភស្តុតាងដែលត្រូវបានទទួលយក និងកោះហៅជាថ្មី សាក្សីដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២ ។

១. នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់សារណាទាក់ទងនឹងទម្រង់សម្រាប់ការប្រើប្រាស់ភស្តុតាងដែលទទួលយកនៅក្នុងសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង ០០២/០២ និងនីតិវិធីសម្រាប់ការកោះហៅជាថ្មីចំពោះសាក្សីដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២ ("សារណាភស្តុតាងរបស់សហព្រះរាជអាជ្ញា")[1]។ អនុលោមតាមការណែនាំលើកមុនពីអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារបានដាក់សារណាទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ("សារណាពីវិសាលភាព")[2]។ តាមរយៈការជូនដំណឹងតាមសារអេឡិចត្រូនិច អង្គជំនុំជម្រះបានពន្យាពេលដល់ភាគីដាក់ចម្លើយតបទៅនឹងសារណាភស្តុតាងរបស់សហព្រះរាជអាជ្ញា រហូតដល់ថ្ងៃទី៣ ខែ កុម្ភៈ ឆ្នាំ ២០១៤។

២. សារណាភស្តុតាងរបស់សហព្រះរាជអាជ្ញាស្វែងរកការសម្រេចមួយថា: ក) ភស្តុតាងទាំងអស់ដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២/០១ និងត្រូវបានចាត់លេខជា E3 នឹងត្រូវបានពិចារណាថា ត្រូវបានដាក់យ៉ាងត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីទាំងអស់ទាក់ទងនឹងការចោទប្រកាន់ដែលសេសសល់ និង ខ) សាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ អាចត្រូវបានកោះហៅជាថ្មីនៅក្នុងការជំនុំជម្រះសំណុំរឿង០០២/០២ បើសិនភាគីដែលស្នើសុំ

---

[1] ឯកសារ E302 "សារណារបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រើព័ស្តុតាង និងនីតិវិធីសម្រាប់ការកោះហៅជាថ្មីសាក្សីពីសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២" ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ("សារណាព័ស្តុងតាងរបស់សហព្រះរាជអាជ្ញា")។

[2] ឯកសារ **E301/5/4**, "ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យភាគីដាក់សារណាទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ។

ឲ្យតុលាការជឿថា ការតាំងសំណួរបន្ថែមមានប្រយោជន៍ដល់យុត្តិធម៌នោះ"[3]។ ក្រុមមេធាវីការពារយល់ស្របទាំងស្រុងជាមួយសំណើលើកដំបូងរបស់សហព្រះរាជអាជ្ញា និងយល់ស្របមួយផ្នែកជាមួយសំណើលើកទីពីរ។

*ភាពអាចទទួលយកបាននៃភស្តុតាងដែលបានទទួលយកនៅករណី០០២/០១*

៣. ក្រុមមេធាវីការពារយល់ស្របជាមួយសហព្រះរាជអាជ្ញាថា ឯកសារដែលបានទទួលយកនៅក្នុងសំណុំរឿង០០២/០១ ត្រូវតែបានចាត់ទុកថាអាចទទួលយកបាននៅក្នុងសំណុំរឿង០០២/០២[4]។ ជំហរនោះជាមួយសារណាវិសាលភាពរបស់ នួន ជា ដែលបានលើកអំណះអំណាងថា អង្គជំនុំជម្រះគប្បីពិចារណាភស្តុតាងដែលមានអង្គហេតុនៅក្នុងដីកាដំណោះស្រាយទាំងមូលដែលត្រូវតែពាក់ព័ន្ធជាមួយការចោទប្រកាន់នៅក្នុងករណី០០២/០២[5]។

*សាក្សីដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១*

៤. ក្រុមមេធាវីការពារយល់ស្របមួយផ្នែកជាមួយសហព្រះរាជអាជ្ញាថា សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបានកោះហៅជាថ្មីនៅក្នុងសំណុំរឿង០០២/០២ ក្នុងករណីដែលការចូលខ្លួនរបស់គាត់មានប្រយោជន៍ដល់យុត្តិធម៌។ ក្រុមមេធាវីការពារយល់ស្របថាភាគី អាចស្នើសុំឲ្យផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២ នៃសាក្សីណាមួយដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១។ ប៉ុន្តែក្រុមមេធាវីការ

---

[3] សារណាព័ត្មុងតាងរបស់សហព្រះ រាជអាជ្ញា នៅកថាខណ្ឌ១។

[4] ជំហររបស់ក្រុមមេធាវីការពារជាមួយការប្រយ័ត្នប្រយែង: ខ្លួននៅចាំមើលថា តើអង្គជំនុំជម្រះពឹងផ្អែកលើឯកសារជាក់លាក់ដែលមេធាវីការពារបានជំទាស់ក្នុងសំណុំរឿង ០០២/០១ ឬក៏អត់ ហើយខ្លួននឹងស្វែងរកការប្តឹងសារទុក្ខទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះទាក់ទងបទដ្ឋានដែលយកមកអនុវត្តចំពោះការទទួលយកព័ស្តុតាង "នៅពេលដំណាលគ្នា" នឹងបណ្តឹងសារទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រម ។ សូមមើលវិធាន១០៤(៤)។ ក្រុមមេធាវីការពាររក្សាសិទ្ធិជំទាស់ព័ស្តុតាងដែលទទួលយកនៅក្នុងសំណុំរឿង០០២/០១ ដោយអង្គជំនុំជម្រះ ដោយរង់ចាំការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល និង សាលក្រមលើសំណុំរឿង០០២/០១។

[5] សារណាវិសាលភាព កថាខណ្ឌ ៤ ។

ពារមិនយល់ស្របថា លក្ខណៈវិនិច្ឆ័យពិសេស ត្រូវអនុវត្តចំពោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង00២/0១។ ជំនួសមកវិញអង្គជំនុំជម្រះគប្បីពិចារណាថា តើសាក្សីនីមួយៗ បម្រើគោលដៅរបស់អង្គជំនុំជម្រះនៃការវាយតម្លៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងករណី00២/0២ ដែរ ឬយ៉ាងណា[6]។

៥. ក្រុមមេធាវីការពារសង្កត់ធ្ងន់ថា (ដូចដែលធ្លាប់បានធ្វើច្រើនលើករួចមកហើយ) ខ្លួនត្រូវបាន និងតែងតែត្រូវបានហាមឃាត់ពីការស៊ើបសួរដោយខ្លួនឯង ឬចូលរួមក្នុងកិច្ចស៊ើបសួរដែលដឹកនាំដោយសហចៅក្រមស៊ើបអង្កេត[7]។ ការដាក់សំណួរទៅកាន់បដិសាក្សីនៅសវនាការដែលបានចាប់ផ្តើមរយៈពេលជាងបួនឆ្នាំក្រោយពីការចាប់ខ្លួន នួន ជា លើកដំបូង ជាឱកាសតែមួយគត់របស់ នួន ជា ដើម្បីស៊ើបអង្កេតលើអង្គហេតុនានាដើម្បីគាំទ្រដល់ការការពាររបស់គាត់។ អង្គហេតុទាំងនេះត្រូវបានដាក់បញ្ចូលជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនេះ នៅពេលដំណាលគ្នាដែលក្រុមមេធាវីការពារដឹងជាលើកដំបូងបំផុតពីភស្តុតាងទាំងនោះ។

៦. ទាក់ទងនឹងបញ្ហានេះ ក្រុមមេធាវីការពារមានស្ថានភាពខុសពីសហព្រះរាជអាជ្ញាដែលបានស៊ើបសួរបឋមដោយខ្លួនឯង នៅមុនការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងកំណត់ព្រំដែន និងទិសដៅសម្រាប់ការស៊ើបអង្កេត[8]។ បន្ថែមពីលើនេះការស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញាទៅក្នុងអង្គហេតុ គឺលម្អៀងទាំងស្រុង (ដោយមិនគិតពីការសច្ចធារណ៍នៃ

---

[6] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២។

[7] ឯកសារ **A110/I** លិខិតរបស់ កសចស "ចម្លើយបតទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី ២0 ខែ ធ្នូ ឆ្នាំ ២00៧ ទាក់ទងនឹងការស៊ើបអង្កេត" ថ្ងៃទី ១0 ខែ មករា ឆ្នាំ ២00៨។ ឯកសារលេខ **E251** "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីទាក់ទងនឹងការចោទប្រកាន់មានភាពមិនប្រក្រតី កើតមានឡើងក្នុងអំឡុងពេលស៊ើបអង្កេត(E221, E223, E224, E224/2, E234, E234/2, E241 and E241/1)" ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២0១២ កថាខណ្ឌ ៣៧ ដល់ ៣៨។

[8] សូមមើល វិធាន ៥៣(១), (២), វិធាន ៥៥(២),(៣) និងមើលផងដែរឯកសារ. **D130/11** "សំណើរសុំឲ្យមានការស៊ើបអង្កេតលើកទី១៥" ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២00៩ កថាខណ្ឌ ៤។

និរទោសនៅចំពោះមុខអង្គជំនុំជម្រះនេះ)[9]។ ជាជាងការពិចារណាសមរម្យលើទសន្សទាននៃភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ការស៊ើបអង្កេតនេះផ្តោតតែទៅលើការកសាងសំណុំរឿងប្រឆាំងនឹងជនជាប់ចោទ នៅមុនពេលដែល នួន ជា ត្រូវបានអនុញ្ញាតឲ្យចាប់ផ្តើមតបត។ សារសំខាន់នៃការសាកសួរបដិសាក្សី គឺកាន់តែមានសារសំខាន់ច្រើនទៀត ដោយសារផលវិបាកនៃការស៊ើបអង្កេតនេះ។

៧. សម្រាប់មូលហេតុទាំងនេះ ការវាយតម្លៃដែលស្នើដោយសហព្រះរាជអាជ្ញាថា តើការស្តាប់ឡើងវិញនៃសក្ខីកម្មរបស់សាក្សី ជា"ប្រយោជន៍យុត្តិធម៌") ដែរ ឬយ៉ាងនោះ គឺស្រពិចស្រពិលខ្លាំងណាស់ និងមិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះសិទ្ធិរបស់ជនជាប់ចោទ ដើម្បីតទល់ភស្តុតាងប្រឆាំងនឹងគាត់។ ជនជាប់ចោទមិនត្រូវតម្រូវជំទាស់សច្ចធារណ៍ប្រឆាំង នឹងអ្វីដែលហៅថា "ការកោះហៅជាថ្មី" សាក្សីនៅក្នុងសំណុំរឿង០០២/០២ ឡើយ។ ក្នុងសំណុំរឿង ០០២/០២ គឺជាការជំនុំជម្រះដាច់ដោយឡែក ជាមួយការចោទប្រកាន់ផ្សេង-អាចជាចៅក្រមផ្សេង។ ប្រការដែលថាសាក្សីដែលត្រូវបានកោះហៅផ្តល់សក្ខីកម្មរួចមកហើយនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ អាចថាជាកត្តាពាក់ព័ន្ធនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះទាក់ទងនឹងភាពសមរម្យនៃស្តាប់សក្ខីកម្មសារឡើងវិញនៃសាក្សីណាម្នាក់នោះ។ វាមិនអាចជាចំណុចចាប់ផ្តើមពីអ្វីដែលអង្គជំនុំជម្រះ ត្រូវតែ"សម្រេច" ថាការបត់បែនគឺចាំបាច់ និង "មិនពន្យាដំណើរការនីតិវិធីមិនត្រឹមត្រូវឡើយ"[10]។

៨. ក្រុមមេធាវីការពារកត់សម្គាល់បន្ថែមទៀតថា អនុលោមតាមសហព្រះរាជអាជ្ញាភាគីអាចសាកសួរអ្នកជំនាញ និងសាក្សីវ័យចំណាស់លើប្រធានបទណាមួយក្នុងវិសាលភាពនៃដីកាដំណោះស្រាយទាំងមូលក្នុងសំណុំរឿង០០២[11]។ សហព្រះរាជអាជ្ញាត្រូវមួយផ្នែកប៉ុណ្ណោះ។ អង្គជំនុំជម្រះយល់ឃើញថា បើទោះជាភាគីត្រូវបានអនុញ្ញាតឲ្យដាក់សំណួរទៅអ្នកជំនាញ

---

[9] សូមមើល ឯកសារ. E295/6/3 "សេចក្តីសន្និដ្ឋានបញ្ចប់នៅក្នុងសំណុំរឿង ០០២/០១ របស់ នួន ជា" ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧ ដល់ ៣៧។

[10] សារណាព័ស្តុងតាងរបស់សហព្រះ រាជអាជ្ញា នៅកថាខណ្ឌ៩ ។

[11] សារណាព័ស្តុងតាងរបស់សហព្រះ រាជអាជ្ញា នៅកថាខណ្ឌ៤ ។

ទាក់ទងនឹងអង្គហេតុណាមួយនៅក្នុងវិសាលភាពនៃដីកាដំណោះស្រាយ ក៏ពួកគេត្រូវបានលើកទឹកចិត្តឱ្យផ្តោតតែទៅលើប្រធានបទនៅក្នុងវិសាភាពនៃសំណុំរឿង០០២/០១[12]។ ហេតុដូច្នេះ អង្គជំនុំជម្រះទទួលស្គាល់ថា ពេលវេលាដែលបែងចែកឱ្យភាគីនីមួយៗ មិនគ្រប់គ្រាន់សម្រាប់ការសាកសួរសាក្សីទាក់ទងនឹងដីកាដំណោះស្រាយទាំងមូលឡើយ។ ក្នុងន័យនេះភាគីមិនត្រូវបានអនុញ្ញាតឱ្យតាំងសំណួរដល់អ្នកជំនាញទាក់ទងនឹងដីកាដំណោះស្រាយទាំងមូលទេ។

៩. ក្រុមមេធាវីការពារកត់សម្គាល់ថា មានតែអ្នកជំនាញពីរនាក់ប៉ុណ្ណោះដែលបានចូលខ្លួនមកបំភ្លឺក្នុងសំណុំរឿង០០២/០១ ទាក់ទងនឹងសារធាតុនៃដីកាដំណោះស្រាយ នោះគឺ David Chandler និង Philip Short។ មានតែសាក្សីជាមនុស្សចាស់មួយចំនួនតូចប៉ុណ្ណោះ ត្រូវបានស្តាប់សក្ខីកម្មទាក់ទងនឹងដីកាដំណោះស្រាយទាំងមូល[13]។ អាស្រ័យហេតុដូច្នេះមិនមានហានិភ័យចំពោះសក្ខីកម្មច្រំដែលនោះទេ។ ម្យ៉ាងទៀត ក្រុមមេធាវីការពារ នួន ជា មិនមានបំណងស្វែងរកឱ្យការចូលខ្លួននៃអ្នកជំនាញ Philip Short នៅក្នុងសំណុំរឿង០០២/០២ ទេ។ ភាគីមួយផ្សេងទៀត គឺសហព្រះរាជអាជ្ញាក៏ទេដែរ[14]។

១០. ប៉ុន្តែការផ្តល់សក្ខីកម្មរបស់ Chanlder នៅក្នុងសំណុំរឿង០០២/០២ គឺមានសារៈសំខាន់។ Chanlder បានសរសេរយ៉ាងទូលំទូលាយអំពីស២១ ហើយគាត់ជាមនុស្សម្នាក់នៅក្នុងចំណោមមនុស្សមួយក្តាប់តូច ដែលបានពិនិត្យយ៉ាងល្អិតល្អន់នូវចម្លើយសារភាពដើមជាភាសាខ្មែរនៅស២១ ។ ចម្លើយសារភាពទាំងនេះគឺជាចំណុចស្នូលនៃការរកឃើញរបស់គាត់ និងអ្នកប្រវត្តិវិទូដ៏ដទៃទៀតទាក់ទងនឹងស២១ និងបញ្ហាធំៗដ៏ទៃទៀត ដូចជាការបែកបាក់គ្នារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាចំណុចស្នូលនៃការការពារក្តីរបស់ នួន ជា ក្នុងសំណុំរឿង

---

[12] ឯកសារ **E1/189.1** "ប្រតិចារិតនៃដំណើរការនីតិវិធី" ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ 1:18-25។

[13] សូមមើលឧទាហរណ៍ឯកសារ E188.1 "ឧបសម្ព័ន្ធសម្ងាត់ក: បញ្ជីសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាយុចាប់ពី៧០ឆ្នាំឡើងទៅ" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ (មានឈ្មោះសាក្សីជាមនុស្សចាស់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១១នាក់ ដែលត្រូវស្តាប់សក្ខីកម្មទាក់ទងនឹងដីកាដំណោះស្រាយទាំងមូល)។

[14] ឯកសារ E301/2/1.1 ""ឧបសម្ព័ន្ធសម្ងាត់ក: ផែនការសវនាការ និង បញ្ជីសាក្សីបណ្តោះអាសន្នសម្រាប់ករណី ០០២/០២ ចុះថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០១៣ ។

០០២/០២[15]។ ដូចដែលក្រុមមេធាវីការពារបានកត់សម្គាល់ពីលើកមុន សហព្រះរាជអាជ្ញាបាន ពឹងផ្អែកយ៉ាងខ្លាំងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ពួកគេពីប្រភពមិនផ្ទាល់ និងអ្វីដែលហៅថា សក្ខីកម្មរបស់អ្នកជំនាញ[16]។ ជាការពិត Chanlder បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០១ ហើយសហព្រះរាជអាជ្ញាបានបានស្នើសុំឲ្យទទួលយកសក្ខីកម្មរបស់គាត់ជាភស្តុតាងក្នុងសំណុំ រឿង ០០២[17]។ ឱកាសដាក់សំណួរទៅលើលោក Chanlder ទាក់ទងនឹងវិធីសាស្ត្ររបស់គាត់ និងសារធាតុនៃការរកឃើញរបស់គាត់ ដែលជាឱកាសមិនត្រូវបានផ្តល់ឲ្យនៅក្នុងករណី ០០២/០១ គឺឱកាសសំខាន់បំផុត។

១១. ជាចុងក្រោយក្រុមមេធាវីការពារកត់សម្គាល់ថា សំណុំរឿង ០០២/០២ ទំនងជាត្រូវបានពន្យា ពេលប៉ុន្មានខែទៀតមុនពេលចាប់ផ្តើមដំណើរការនីតិវិធី។ អង្គជំនុំជម្រះបានកំណត់ពេល សម្រាប់កិច្ចប្រជុំរៀបចំសវនាការតែមួយគត់ក្នុងរយៈពេលបីខែដំបូង និងមួយខែកន្លះ បន្ទាប់ ពីបិទសវនាការនៅក្នុងសំណុំរឿង០០២/០១។ ខណៈដែលក្រុមមេធាវីការពារទទួលស្គាល់ថា ការពន្យាពេលក្នុងកម្រិតមួយ នឹងមិនអាចបញ្ចៀសបាន នៅក្នុងសារណារបស់មេធាវីការពារ ចម្ងាយផ្លូវបច្ចុប្បន្នរបស់សំណុំរឿង០០២/០២ គឺមានចំងាយវែងមិនចាំបាច់ និងមិនសមស្រប ជាមួយការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលទៀតផង[18]។ ក្រុមមេធាវីការពារយល់ ឃើញថា ប្រសិនបើសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ ត្រូវពន្យាពេលរហូត ដល់ជិតមួយឆ្នាំចាប់ពីការបិទការសួរដេញដោលលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ នោះពិចារណាពីប្រសិទ្ធិភាព និងការចំណាយរបស់តុលាការ មិនគួរធ្វើជាមូលដ្ឋានដើម្បី

---

[15] សូមមើលឧទាហរណ៍ Stephen R. Heder, *ខ្មែរក្រហមប្រឆាំងនឹង ប៉ុល ពត* (Khmer Rouge Opposition to Pol Pot)ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩០។

[16] ឯកសារ E1/232.1 "ប្រតិចារិតសវនាការ" ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ នៅទំព័រ17:17-20: 17

[17] ឯកសារ E9/31.11 "ឧបសម្ព័ន្ធ១១ ប្រតិចារិតសំណុំរឿង០១" ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, ចូលចំនួន ៥១។

[18] ឯកសារ E284/4/8 "សេចក្តីសម្រេចលើបណ្តឹងសារទុក្ខជាបន្ទាន់ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកសំណុំរឿង០០២" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅកថាខណ្ឌ៧៦ (បង្គាប់ថាសវនាការលើព័ស្តុតាងនៅក្នុងករណី០០២/០២ ត្រូវចាប់ផ្តើមឲ្យបានឆាប់បំផុត តាមដែលធ្វើបាន" បន្ទាប់ពីសេចក្តីសន្និដ្ឋានបិទការសួរដេញដោលលើព័ស្តុងតាងនៃករណី០០២/០១)។

កម្រិតការស្តាប់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះឡើយ។ វាជាគោលបំណងនៃសវនាការស្តាប់សក្ខីកម្ម និងមិនមែនដំណើរការដ៏វែងនៃការគាំទ្រខ្លួនឯងក្នុងការស្តាប់សក្ខីកម្ម ដែលស្ថាប័ននេះត្រូវបានបង្កើតឡើង។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE